# ព្រះរាជក្រម

នស/រកម/១២០៦/០២៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមលើពិធីសារកាតាហេហ្សណាស្តីពីជីវសុវត្ថិភាព ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៦ ខែតុលា ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួម
# លើពិធីសារកាតាហេហ្សណាស្តីពីជីវសុវត្ថិភាព

**មាត្រា ១.-**

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមលើពិធីសារកាតាហេហ្សណាស្តីពី ជីវសុវត្ថិភាព ដែលធ្វើនៅទីក្រុងម៉ុងរ៉េអាល់ នៃប្រទេសកាណាដា នាថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០០ ហើយដែលមានអត្ថបទទាំងស្រុង ភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តពិធីសារនេះ ។

រាជធានីភ្នំពេញថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០០៦

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

នស/រកម.០៦១២.៥៣៤

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ចករ

ជា ស៊ីម

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន
ហត្ថលេខា
ម៉ុក ម៉ារ៉េត

លេខ : ៤៨៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០០៦
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
[illegible] ធីកេន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៧៣...អនក្រ.បក

**សេចក្តីថ្លែងហេតុ**

**នៃសេចក្តីព្រាងច្បាប់**

**ស្តីពី**

**ការអនុម័តយល់ព្រមលើពិធីសារកាតាហ្សេណាស្តីពីជីវសុវត្ថិភាព**

ពិធីសារកាតាហ្សេណាស្តីពីជីវសុវត្ថិភាពបានរៀបចំឡើង និងអនុម័តដោយសន្និសីទនៃភាគីចុះកិច្ចសន្យា នៅថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០២។ ពិធីសារនេះមានគោលបំណងការពារជីវៈចម្រុះ ឱ្យរួចផុតពីគ្រោះថ្នាក់ដែលបង្កដោយសពាង្គកាយកែច្នៃរស់ ដែលជាលទ្ធផលនៃបច្ចេកវិទ្យាទំនើប។ ពិធីសារនេះ បានបង្កើតនូវបែបបទព្រមព្រៀងជូនព័ត៌មានជាមុន ដែលធ្វើការធានាថាប្រទេសនីមួយៗត្រូវផ្តល់ព័ត៌មានចាំបាច់សម្រាប់ធ្វើសេចក្តីសម្រេចមុននឹងឯកភាពនាំចូលសពាង្គកាយបែបនេះទៅក្នុងទឹកដីរបស់ខ្លួន។

ពិធីសារនេះ ត្រូវបានរៀបចំឡើងដោយយោងតាមមាត្រា១៩ កថាខ័ណ្ឌ៣និង៤ នៃមាត្រា១៧ និង១៨ នៃអនុសញ្ញាអន្តរជាតិស្តីពីជីវៈចម្រុះ ដែលព្រះរាជាណាចក្រយើងបានក្លាយជាសមាជិក នៅថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ រួចមកហើយ។ ពិធីសារនេះមាន ៤០ មាត្រា ហើយនិងមានប្រទេសជាង ៥០ បានផ្តល់សច្ចានុម័តរួចហើយ។

-ហេតុអ្វីបានជាចាំបាច់ចូលរួមពិធីសារកាតាហ្សេណាស្តីពីជីវសុវត្ថិភាពនេះ? ហេតុផលមានច្រើនដែលទាក់ទងនឹងផ្លូវច្បាប់ និងផលប្រយោជន៍ ÷

**១-នយោបាយ**

ព្រះរាជាណាចក្រកម្ពុជា បានចូលជាសមាជិកនៃអនុសញ្ញាអន្តរជាតិស្តីពីជីវៈចម្រុះ ដែលពិធីសារកាតាហ្សេណាស្ថិតនៅក្រោមអនុសញ្ញានេះ។ យោងតាមមាត្រា៩នៃអនុសញ្ញាស្តីពីជីវៈចម្រុះ ប្រទេសយើងត្រូវតែបំពេញកាតព្វកិច្ចក្នុងការរៀបចំផែនការនយោបាយ ដើម្បីគ្រប់គ្រងជីវសុវត្ថិភាព និងបច្ចេកវិទ្យា។ ក្រោយមកយោងតាមអនុសាសន៍សន្និសីទភាគីចុះកិច្ចសន្យា បានសំណូមពរឱ្យប្រទេសដែលចូលជាភាគីនៃអនុសញ្ញានេះស្តីពីជីវៈចម្រុះ ចុះហត្ថលេខា ឬផ្តល់សច្ចាប័នដល់ពីធីសារកាតាហ្សេណាស្តីពីជីវសុវត្ថិភាពឱ្យបានឆាប់។

២- ផលប្រយោជន៍សេដ្ឋកិច្ច

-ការពារផលិតផលកសិកម្ម សត្វ និងរុក្ខជាតិក្នុងស្រុក ដើម្បីកុំឱ្យមានការឈ្លានពានដោយផលិតផលសរីរាង្គកាយកែច្នៃរស់ និងសរីរាង្គកាយកែច្នៃដែលនាំចូលពីខាងក្រៅ និងបង្កឱ្យមានការប៉ះពាល់ប្រភេទក្នុងស្រុក ។

-ទទួលជំនួយពីអង្គការមូលនិធិបរិស្ថានពិភពលោក ដើម្បីរៀបចំក្របខ័ណ្ឌជីវសុវត្ថិភាពជាតិ ក្នុងការទប់ស្កាត់គ្រោះថ្នាក់ ដែលបណ្តាលមកពីគ្មានការត្រួតពិនិត្យត្រឹមត្រូវ ឬការតាមដានការនាំចូលផលិតផល សរីរាង្គកាយកែច្នៃរស់ និងសរីរាង្គកាយកែច្នៃមកពីក្រៅប្រទេស ។

-បណ្តុះបណ្តាលមន្ត្រីរាជការលើមុខវិជ្ជាពាក់ព័ន្ធ ឬសមត្ថភាពស្ថាប័ន ក្នុងការគ្រប់គ្រងសរីរាង្គកាយកែច្នៃរស់ និងសរីរាង្គកាយកែច្នៃ ដូចជាការវាយតម្លៃហានិភ័យ និងគ្រប់គ្រងហានិភ័យ ។

-ដើរទាន់និន្នាការពិភពលោក និងតំបន់លើវិស័យជីវៈចម្រុះ និងការគ្រប់គ្រងជីវសុវត្ថិភាព ។

៣- សមាហរណកម្មអន្តរជាតិ

-កិច្ចប្រជុំរដ្ឋមន្ត្រីខាងផ្នែកកសិកម្ម និងរុក្ខា ដែលរៀបចំឡើង នៅថ្ងៃទី២៨-២៩ ឆ្នាំ ១៩៩៩ នៅប្រទេសប្រ៊ុយណេ បានសំណូមពរឱ្យប្រទេសនីមួយៗ បង្កើតអាជ្ញាធរទទួលខុសត្រូវកែតម្រូវលើសេនេទិច ។ អង្គប្រជុំក៏បានឯកភាពលើគោលការណ៍ណែនាំស្តីពីការវាយតម្លៃគ្រោះថ្នាក់បណ្តាលមកពីសរីរាង្គកាយកែសម្រួលសេនេទិចទាក់ទងនឹងផ្នែកកសិកម្ម ។ តែទោះបីជាយ៉ាងណាក៏ដោយក៏គោលការណ៍នេះ ពុំទាន់មានប្រសិទ្ធភាពលើច្បាប់នេះឡើយ ។

៤- ផលប្រយោជន៍ផ្សេងៗទៀតដែលមិនអាចវាស់វែងបាន ដែលប្រទេសកម្ពុជាយើងនឹងទទួលពីការចូលជាសមាជិកនៃពិធីសារនេះ ដូចជាការពង្រឹងសមត្ថភាពផ្នែកស្ថាប័ន និងប្រព័ន្ធសម្រាប់ការគ្រប់គ្រងសរីរាង្គកាយកែច្នៃរស់ជាដើម ។

អាស្រ័យសេចក្តីដូចបានទូលថ្វាយ និងជម្រាបជូនខាងលើ សូមរដ្ឋសភាមេត្តាពិនិត្យ និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារកាតាហ្សេណាស្តីពីជីវសុវត្ថិភាពនេះ ដោយអនុគ្រោះ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ក្រសួងបរិស្ថាន

បកប្រែក្រៅផ្លូវការ



# ពិធីសារកាតាហ្សេណា ស្តីពីជីវសុវត្ថិភាពនៃអនុសញ្ញាស្តីពីជីវៈចំរុះ

ភាគីចុះកិច្ចសន្យាទៅនឹងពិធីសារនេះ :

ជាភាគីនៃអនុសញ្ញាអន្តរជាតិស្តីពីជីវៈចំរុះ យោងទៅតាមអនុសញ្ញានេះ ។

បានឃើញមាត្រាទី ១៩ ក្នុងឃ្លាទី ៣ និងទី៤ ហើយនឹងមាត្រាទី ៨ (g) និងទី ១៧នៃអនុសញ្ញានេះ ។

បានឃើញសេចក្តីសំរេច II/៥ នៃសន្និសីទភាគីអនុសញ្ញាទាំងអស់ ដើម្បីធ្វើការកែសំរួលពិធីសារ ស្តីពីជីវសុវត្ថិភាព នៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ដោយផ្តោតការយកទុកដាក់ជាពិសេសទៅលើចលនាឆ្លងដែននៃសារពាង្គកាយកែច្នៃរស់ ដែលជាលទ្ធផលនៃបច្ចេកវិទ្យាទំនើប ហើយអាចបង្កអោយមានឥទ្ធិពលអវិជ្ជមានដល់ការអភិរក្ស និងនិរន្តរភាពនៃការប្រើប្រាស់ធនធានជីវៈចំរុះ ដែលកំណត់ចេញសំរាប់ធ្វើការពិចារណាទៅលើនីតិវិធីសមស្របសំរាប់ការព្រមព្រៀងដែលផ្តល់ព័ត៌មានជាមុន ។

ដោយធ្វើការអះអាងជាថ្មីឡើងវិញនូវវិធានការណ៍ការពារដែលមាននៅក្នុងគោលការណ៍ទី ១៥ នៃសេចក្តីប្រកាស Rio ស្តីពីបរិស្ថាន និងការអភិវឌ្ឍន៍ ។

ដោយយល់ដឹងពីការរីកចំរើននៃជីវបច្ចេកវិទ្យាទំនើប និង ការកើនឡើងនូវការព្រួយបារម្ភរបស់សាធារណៈពីឥទ្ធិពលអវិជ្ជមានទៅលើធនធានជីវៈចំរុះ និងសុខភាពមនុស្ស ។

ដោយទទួលស្គាល់ថា ជីវបច្ចេកវិទ្យាទំនើបមានអត្ថប្រយោជន៍យ៉ាងច្រើនសំរាប់មនុស្សលោក ប្រសិនបើត្រូវបានប្រើប្រាស់ដោយមានវិធានការណ៍សុវត្ថិភាពត្រឹមត្រូវសំរាប់បរិស្ថាន និងសុខភាពមនុស្ស ។

ដោយទទួលស្គាល់ផងដែរនូវសារៈសំខាន់ដល់ប្រភពមជ្ឈមណ្ឌលដើមកំណើតរបស់មនុស្សលោក និងមណ្ឌលសេនេទិច ចំរុះ

ដោយដឹងថាសមត្ថភាពនៃប្រទេសជាច្រើននៅមានកំរិត ជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីដោះស្រាយគ្រោះថ្នាក់មកពីធម្មជាតិ និងកំរិតនៃគ្រោះថ្នាក់ធំៗដែលបណ្តាលមកពីសារពាង្គកាយកែច្នៃរស់ ។

ដោយទទួលស្គាល់ថាកិច្ចព្រមព្រៀងពាណិជ្ជកម្ម និងកិច្ចព្រមព្រៀងបរិស្ថានត្រូវមានទំនាក់ទំនងគ្នាទៅវិញទៅមក ដើម្បីសំរេចអោយបាននូវការអភិវឌ្ឍន៍ប្រកបដោយចីរភាព ។

ដោយកត់សំគាល់ផងដែរថា ពិធីសារនេះនឹងមិនត្រូវបានបកស្រាយទៅលើការឆ្លុះបញ្ចាំងនូវការផ្លាស់ប្តូរសិទ្ធិ និងកាតព្វកិច្ចនៃ ភាគីចុះកិច្ចសន្យានៅក្រោមកិច្ចព្រមព្រៀងអន្តរជាតិដែលមានស្រាប់ ។

ដោយយល់ឃើញថា រាល់ចំនុចដែលបានរៀបរាប់ខាងលើនេះ ពុំមានបំណងដាក់ពិធីសារនេះអោយរណបទៅនឹងកិច្ចព្រមព្រៀងអន្តរជាតិដទៃទៀតទេ ។

ភាគីចុះកិច្ចសន្យាបានឯកភាពខាងក្រោម :

## មាត្រានី ១
## គោលបំណង

អនុលោមទៅតាមវិធានការណ៍ប្រុងប្រយ័ត្នដែលចែងនៅក្នុងគោលការណ៍ទី១៥ នៃសេចក្តីប្រកាសទីក្រុង Rio ស្តីពីបរិស្ថាន និងការអភិវឌ្ឍន៍ គោលបំណងនៃពិធីសារនេះ គឺដើម្បីរួមវិភាគទានក្នុងការធានាកំរិតការពារឱ្យបានសមស្រប នៅក្នុងការផ្ទេរ ការគ្រប់គ្រង និងការប្រើប្រាស់ឱ្យមានសុវត្ថិភាពនៃសារពាង្គកាយកែច្នៃរស់ ដែលជាលទ្ធផលនៃជីវបច្ចេកវិទ្យាទំនើប ដែលអាចនាំមកនូវផលប៉ះពាល់អវិជ្ជមានដល់ការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនូវធនធានជីវៈចំរុះដោយគិតគូអំពីគ្រោះថ្នាក់ដល់សុខភាពមនុស្ស និងជាពិសេសផ្តោតការចាប់អារម្មណ៍សំខាន់ទៅលើចលនាឆ្លងដែនផងដែរ ។

## មាត្រានី ២
## លក្ខខណ្ឌទូទៅ

១. ភាគីនីមួយៗនៃពិធីសារអន្តរជាតិនេះ ត្រូវប្រកាន់យកនូវវិធានការច្បាប់ គ្រប់គ្រងសមស្រប និងចាំបាច់ និងវិធានការណ៍ផ្សេងៗទៀត ដើម្បីប្រតិបត្តិកាតព្វកិច្ចរបស់ខ្លួនដែលមានចែងនៅក្នុងពិធីសារនេះ ។

២. ភាគីត្រូវធានាថា ការអភិវឌ្ឍន៍ ការគ្រប់គ្រង ការដឹកជញ្ជូន ការប្រើប្រាស់ ការផ្ទេរ និងការបញ្ចេញនូវសារពាង្គកាយកែច្នៃរស់ត្រូវបានធ្វើឡើងក្នុងគោលបំណងការពារ ឬ ការកាត់បន្ថយគ្រោះថ្នាក់ដល់ជីវៈចំរុះ ដោយត្រូវគិតគូរពីគ្រោះថ្នាក់ដល់សុខភាពមនុស្សផងដែរ ។

៣. ពុំមានចំនុចណាមួយនៅក្នុងពិធីសារនេះ ប៉ះពាល់ទៅលើអធិបតេយ្យភាពដែនសមុទ្ររបស់រដ្ឋទាំងអស់ដែលបានបង្កើតឡើងដោយអនុលោមទៅតាមច្បាប់អន្តរជាតិនោះទេ ហើយសិទ្ធិអធិបតេយ្យភាព និងដែនសមត្ថកិច្ចដែលរដ្ឋទាំងនោះមានបញ្ជាក់នៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ (Exclusive Economic Zone) របស់ខ្លួន និងកិច្ចការពារទ្វីបរបស់គេដោយផ្អែកទៅតាមច្បាប់អន្តរជាតិ ព្រមទាំងការប្រើប្រាស់សិទ្ធិ និងសេរីភាពក្នុងការធ្វើចរាចរផ្លូវទឹក និងផ្លូវអាកាសរបស់ប្រទេសនីមួយៗ ដូចមានចែងក្នុងច្បាប់អន្តរជាតិ និងបានឆ្លុះបញ្ចាំងនៅក្នុងច្បាប់អន្តរជាតិពាក់ព័ន្ធនានា ។

៤. គ្មានចំនុចណាមួយនៃពិធីសារនេះ ត្រូវបានបកស្រាយថាជាការដាក់កំហិតសិទ្ធិរបស់ភាគីណាមួយក្នុងការចាត់វិធានការណ៍ការពារបន្ថែមនៃការប្រើប្រាស់ និងការអភិរក្សជីវៈចំរុះដោយនិរន្តរភាពច្រើនជាងការអំពាវនាវដែលបញ្ជាក់ក្នុងពិធីសារនេះទេ ចែងថាវិធានការណ៍នេះគឺស្របទៅនឹងគោលបំណង និង "ខ" នៃពិធីសារនេះ ហើយអនុលោមទៅនឹងកាតព្វកិច្ចដទៃទៀតរបស់ភាគីផ្សេងទៀតដែលស្ថិតនៅក្រោមច្បាប់អន្តរជាតិ ។

៥. ភាគីទាំងអស់ត្រូវបានជំរុញឱ្យធ្វើការពិចារណាឱ្យបានសមស្របទៅលើជំនាញដែលមានស្រាប់ ឧបករណ៍ ច្បាប់ និងការងារដែលអនុវត្តក្នុងវេទិការអន្តរជាតិ រួមជាមួយនឹងសមត្ថកិច្ចនៅក្នុងផ្នែកគ្រោះថ្នាក់ដល់សុខភាពមនុស្ស ។

## មាត្រានី ៣
## ការប្រើប្រាស់ពាក្យ

សំរាប់គោលបំណងនៃពិធីសារនេះ :

១. "**សន្និសីទភាគី**" មានន័យថាជាសន្និសីទនៃភាគីទាំងអស់ដែលចុះកិច្ចសន្យាទៅនឹងអនុសញ្ញា ។

២. "**ព្រំដែននៃការប្រើប្រាស់**" មានន័យថាជាការប្រើប្រាស់ណាមួយ ដែលធ្វើឡើងនៅក្នុងឧបករណ៍ សំភារៈតំឡើង ការផ្ទុក ឬរចនាសម្ព័ន្ធរូបសាស្ត្រទាក់ទងទៅនឹងសារពាង្គកាយកែច្នៃរស់ ដែលត្រូវបានត្រួតពិនិត្យដោយវិធានការណ៍ច្បាស់លាស់ ដែលកាត់បន្ថយយ៉ាងសាកសិទ្ធនូវការប៉ះពាល់ផ្ទាល់ជាមួយសារពាង្គកាយនោះ និងប៉ះពាល់លើបរិស្ថានខាងក្រៅ ។

៣. " **ការនាំចេញ** " មានន័យថាចលនាឆ្លងដែនអន្តរជាតិពីភាគីមួយទៅភាគីមួយទៀត ។

៤. " **អ្នកនាំចេញ** " មានន័យថានីតិបុគ្គល ស្ថិតនៅក្រោមដែនសមត្ថកិច្ចនៃភាគីចុះកិច្ចសន្យានាំចេញ ដែលជាអ្នកចាត់ចែងធ្វើការនាំចេញនូវសារពាង្គកាយកែច្នៃរស់ ។

៥. " **ការនាំចូល** " មានន័យថាចលនាឆ្លងដែនអន្តរជាតិ ពីភាគីមួយទៅភាគីមួយទៀត

៦. " **អ្នកនាំចូល** " មានន័យថានីតិបុគ្គលណាមួយ ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចនៃភាគីចុះកិច្ចសន្យានាំចូល ដែលជាអ្នកចាត់ចែងធ្វើការនាំចូលនូវសារពាង្គកាយកែច្នៃរស់ ។

៧. " **សារពាង្គកាយកែច្នៃរស់** " មានន័យថាសាពារង្គកាយរស់ដែលមានផ្ទុកនូវសារធាតុសេនេទិចថ្មី ទទួលយកតាមរយៈការប្រើប្រាស់ជីវបច្ចេកវិទ្យាទំនើប ។

៨. " **សារពាង្គកាយរស់** " មានន័យថាអង្គជីវៈចំរុះទាំងឡាយណា ដែលមានសមត្ថភាពក្នុងការផ្ទេរ ឬ ផលិតឡើងវិញនូវសារធាតុសេនេទិច រួមទាំងសារពាង្គកាយដែលមិនអាចបន្តពូជបាន វីរុស និងវីរ៉ូអ៊ីត ។

៩. " **ជីវបច្ចេកវិទ្យាទំនើប** " មានន័យថាការអនុវត្តន៍នូវ :

ក) បច្ចេកទេសអាស៊ីតនុយក្លេអ៊ិចអាំងវីត្រូ (In-vitro nucleic acid techniques) រួមមានការប្រមូលផ្តុំនូវអាស៊ីតឌីអុកស៊ីរីបូនុយក្លេអ៊ិក (DNA) និងការចាក់អាស៊ីតនុយក្លេអ៊ិចដោយផ្ទាល់ទៅក្នុងកោសិកា ឬសរីរាង្គ ។

ខ) ការលាយចូលគ្នានៃកោសិកាដែលមិនមែនជាគ្រួសារតែមួយ ដែលមានលទ្ធភាពយកឈ្នះនូវការផលិតឡើងវិញតាមលក្ខណៈរូបសាស្ត្រធម្មជាតិ ឬ ឧបសគ្គប្រមូលផ្តុំ ហើយដែលមិនមែនជាបច្ចេកទេសប្រើប្រាស់នៅក្នុងការបង្កាត់ ពូជ ឬ ការជ្រើសរើសតាមរបៀបបុរាណនោះទេ ។

១០. " **អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់** " ជាអង្គការបង្កើតដោយឯករាជ្យនៅក្នុងតំបន់ ដែលសមាជិករបស់វាបានផ្ទេរសមត្ថកិច្ចទាក់ទងនឹងអភិបាលកិច្ចទៅពិធីសារនេះ ហើយដែលបានផ្តល់អំណាចត្រឹមត្រូវតាមនីតិវិធីដើម្បីចុះហត្ថលេខា ផ្តល់សច្ចាប័ន ការទទួលយក ការយល់ព្រម ឬការចូលជាសមាជិកអនុលោមតាមបែបផ្ទៃក្នុង ។

១១. " **ចលនាឆ្លងដែន** " ជាចលនានៃសារពាង្គកាយកែច្នៃរស់ ពីភាគីមួយទៅភាគីមួយទៀត ការពារសំរាប់គោលបំណងនៃមាត្រាទី ១៧ និង ២៤ ចលនាឆ្លងដែន គ្របដណ្តប់ដល់ចលនារវាងភាគីចុះកិច្ចសន្យា និងភាគីមិនចុះកិច្ចសន្យា ។

## មាត្រាទី ៤
## វិសាលភាព

ពិធីសារនេះត្រូវអនុវត្តន៍ចំពោះចលនាឆ្លងដែន ការស្នាក់បណ្តោះអាសន្ន ការគ្រប់គ្រង និងការប្រើប្រាស់សារពាង្គកាយកែច្នៃរស់ ដែលអាចបង្កឱ្យមានផលប៉ះពាល់អាក្រក់លើការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនៃជីវៈចំរុះ ដោយគិតគូពីគ្រោះថ្នាក់ដល់សុខភាពមនុស្សផងដែរ ។

## មាត្រាទី ៥
## ផ្នែកឱសថកម្ម

ថ្វីបើមានចែងនៅក្នុងមាត្រាទី៤ ខាងលើ និងដោយពុំបណ្តាលឱ្យប៉ះពាល់ទៅនឹងសិទ្ធិនៃភាគីណាមួយទាក់ទងនឹងបញ្ហាសារពាង្គកាយកែច្នៃរស់ ការវាយតំលៃគ្រោះថ្នាក់មុននឹងធ្វើសេចក្តីសំរេចលើការនាំចូល ពិធីសារនេះ មិនត្រូវអនុវត្តចំពោះចលនាឆ្លងដែននៃសារពាង្គកាយកែច្នៃរស់ដែលជាឱសថសំរាប់មនុស្សដែលត្រូវបានកំណត់ដោយកិច្ចព្រមព្រៀងអន្តរជាតិ ឬ អង្គការអន្តរជាតិនានា ។

## មាត្រាទី ៦
## ការដឹកជញ្ជូនបណ្តោះអាសន្ន និងព្រំដែននៃការប្រើប្រាស់

១. ថ្វីបើមានចែងនៅក្នុងមាត្រាទី៤ ខាងលើ និងដោយពុំបណ្តាលឱ្យប៉ះពាល់ទៅនឹងសិទ្ធិនៃភាគីណាមួយលើការដឹកជញ្ជូនបណ្តោះ ដើម្បីត្រួតពិនិត្យការដឹកជញ្ជូននៃសារពាង្គកាយកែច្នៃរស់ឆ្លងកាត់ដែនដីរបស់ភាគីនោះ និងដើម្បីជូនព័ត៌មានដល់ប្រព័ន្ធការិយាល័យចែកចាយព័ត៌មាននៃជីវសុវត្ថិភាព សេចក្តីសំរេចរបស់ភាគីនោះទាក់ទងនឹងមាត្រាទី ២ កថាខ័ណ្ឌទី ៣ ស្តីពីការដឹកជញ្ជូនបណ្តោះអាសន្នតាមដែនដីខ្លួននូវនៃសារពាង្គកាយកែច្នៃរស់ណាមួយ " ខ " នៃពិធីសារនេះទាក់ទងទៅនឹងបែបបទព្រមព្រៀងជូនព័ត៌មានជាមុន មិនត្រូវបានអនុវត្តលើការដឹកជញ្ជូនបណ្តោះអាសន្ន សារពាង្គកាយកែច្នៃរស់ ។

២. ថ្វីបើមានចែងនៅក្នុងមាត្រាទី៤ ខាងលើ និងដោយពុំបណ្តាលឱ្យប៉ះពាល់នឹងសិទ្ធិនៃភាគីណាមួយក្នុងការដឹកជញ្ជូនបណ្តោះអាសន្នលើរាល់សារពាង្គកាយកែច្នៃរស់លើការវាយតំលៃគ្រោះថ្នាក់មុននឹងធ្វើសេចក្តីសំរេចលើការនាំចូល និងដើម្បីកំណត់បទដ្ឋានសំរាប់ព្រំដែននៃការប្រើប្រាស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន " ខ " នៃពិធីសារនេះទាក់ទងទៅនឹងបែបបទព្រមព្រៀងជូនព័ត៌មានជាមុន មិនត្រូវអនុវត្តលើចលនាឆ្លងដែននៃសារពាង្គកាយកែច្នៃរស់ ចំពោះព្រំដែននៃប្រើប្រាស់ដែលត្រូវបានអនុវត្តស្របទៅតាមបទដ្ឋានស្តង់ដាររបស់ភាគីនាំចូល ។

## មាត្រាទី ៧
## ការអនុវត្តន៍បែបបទព្រមព្រៀងជូនព័ត៌មានជាមុន

១. យោងមាត្រាទី៥ និង ៦ បែបបទព្រមព្រៀងជូនព័ត៌មានជាមុនក្នុងមាត្រាទី ៨ ១០ និង ១២ ត្រូវអនុវត្តឱ្យបានមុនចលនាឆ្លងដែនដោយចេតនាដំបូងនៃសារពាង្គកាយកែច្នៃរស់ សំរាប់ការនាំចូលដោយចេតនាទៅក្នុងបរិស្ថានរបស់ភាគីនាំចូល ។

២. " ការនាំចូលដោយចេតនាទៅក្នុងបរិស្ថាន " ក្នុងកថាខណ្ឌ័ទី ១ ខាងលើ មិនយោងលើសារពាង្គកាយកែច្នៃរស់សំរាប់ការប្រើប្រាស់ដោយផ្ទាល់ជាចំណីអាហារ ចំណីសត្វ ឬ សំរាប់ការកែច្នៃ ។

៣. មាត្រាទី ១១ ត្រូវអនុវត្តមុនចលនាឆ្លងដែនដំបូងនៃសារពាង្គកាយរស់ដែលកែច្នៃ សំរាប់ការប្រើប្រាស់ដោយផ្ទាល់ជាចំណីអាហារ ចំណីសត្វ ឬ សំរាប់ការកែច្នៃ ។

៤. បែបបទព្រមព្រៀងជូនព័ត៌មានជាមុន មិនត្រូវអនុវត្តចំពោះចលនាឆ្លងដែនដោយចេតនានៃសារពាង្គកាយកែច្នៃរស់ ត្រូវបានកំណត់នៅក្នុងសេចក្តីសំរេចនៃសន្និសីទភាគី ដែលជាកិច្ចប្រជុំរវាងភាគីទាំងអស់ដែលចុះកិច្ចសន្យាទៅនឹងពិធីសារនេះ មិនទំនងជាមានផលប៉ះពាល់អាក្រក់លើការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនៃជីវៈចំរុះ ព្រមទាំងគិតគូពីគ្រោះថ្នាក់ដល់សុខភាពមនុស្សផងដែរ ។

## មាត្រាទី ៨
## ការជូនព័ត៌មាន

១. ភាគីនាំចេញ ត្រូវជូនព័ត៌មាន ឬតំរូវឱ្យអ្នកនាំចេញធ្វើលិខិតជូនព័ត៌មានជាលាយលក្ខណ៍អក្សរដល់អាជ្ញាធរមានសមត្ថកិច្ចជាតិនៃភាគីនាំចូលមុននឹងមានចលនាឆ្លងដែនដោយចេតនានៃសារពាង្គកាយកែច្នៃរស់ ដែលមានចែងនៅក្នុងមាត្រាទី៧ កថាខណ្ឌ័ទី ១ ។ ការជូនដំណឹងនេះយ៉ាងហោចណាស់ត្រូវមានព័ត៌មាន ដូចដែលបានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធទី ១ ។

២. ភាគីនាំចេញត្រូវធានាថា មានតំរូវការផ្លូវច្បាប់ដើម្បីភាពត្រឹមត្រូវនៃព័ត៌មានផ្តល់ជូនដោយអ្នកនាំចេញ ។

## មាត្រាទី ៩
## ការបញ្ជាក់នៃការទទួលសេចក្តីជូនព័ត៌មាន

១. ភាគីនាំចូលត្រូវបញ្ជាក់ពីការទទួលសេចក្តីជូនព័ត៌មានជាលាយលក្ខណ៍អក្សរពីអ្នកជូនដំណឹង នៅក្នុងរយៈពេល ៩០ថ្ងៃ បន្ទាប់ពីទទួលលិខិតនោះ ។

២. ការបញ្ជាក់នៃការទទួលសេចក្តីជូនដំណឹងនោះត្រូវបរិយាយពី :

ក. កាលបរិច្ឆេទនៃការទទួលសេចក្តីជូនព័ត៌មាន

ខ. ថាតើសេចក្តីជូនព័ត៌មាននេះមាន (Prima Facie) ព័ត៌មានដែលមានចែងនៅក្នុងមាត្រាទី ៨ ដែររឺទេ

គ. ថាតើដំណើរការនេះស្របទៅនឹងក្របខណ្ឌច្បាប់ក្នុងប្រទេសនៃភាគីនាំចូល ឬ ស្របទៅនឹងបែបបទមានចែង នៅក្នុងមាត្រាទី ១០ ដែរឬទេ ។

៣. ក្របខ័ណ្ឌច្បាប់ក្នុងប្រទេសយោងទៅនឹងកថាខណ្ឌទី ២ (គ) ខាងលើ ត្រូវតែស្របទៅនឹងពិធីសារនេះ ។

៤. ការខកខាននៃភាគីនាំចូលដើម្បីបញ្ជាក់ពីការទទួលសេចក្តីជូនព័ត៌មាន មិនត្រូវស្តែះបញ្ជាក់ពីការឯកភាពរបស់ ភាគីនោះ ទៅនឹងចលនាឆ្លងដែនដោយចេតនាទេ ។

## មាត្រាទី ១០
## បែបបទធ្វើសេចក្តីសំរេច

១. រាល់សេចក្តីសំរេចទាំងឡាយ ដែលបានធ្វើឡើងដោយភាគីនាំចូលត្រូវអនុលោមទៅតាមមាត្រាទី ១៥ ។

២. ភាគីនាំចូលត្រូវជូនព័ត៌មានជាលាយលក្ខណ៍អក្សរដល់អ្នកជូនព័ត៌មាន (Notifier) ក្នុងរយៈពេលដែលមានចែង នៅក្នុងមាត្រាទី៩ ថាតើចលនាឆ្លងដែនដោយចេតនាអាចដំណើរការបានដែរឬទេ :

ក. បន្ទាប់ពីភាគីនាំចូល បានផ្តល់ការឯកភាពជាលាយលក្ខណ៍អក្សរ

ខ. បន្ទាប់ពីរយៈពេលមិនយឺតជាង ៩០ថ្ងៃ ដោយពុំមានការឯកភាពជាលាយលក្ខណ៍អក្សរ ។

៣. នៅក្នុងរយៈពេល ២៧០ថ្ងៃ នៃកាលបរិច្ឆេទនៃការទទួលសេចក្តីជូនព័ត៌មាន ភាគីនាំចូលត្រូវទាក់ទងជា លាយលក្ខណ៍អក្សរទៅអ្នកជូនព័ត៌មាន និងទៅការិយាល័យចែកចាយព័ត៌មានជីវសុវត្ថិភាព នូវសេចក្តីសំរេចយោងទៅលើ កថាខ័ណ្ឌទី ២ ខាងលើ ចំពោះ :

ក. ការអនុញ្ញាតឱ្យនាំចូលដោយមាន ឬគ្មានលក្ខខ័ណ្ឌ រួមទាំងវិធីដែលសេចក្តីសំរេច នឹងអនុវត្តចំពោះ ការនាំចូលជាបន្តបន្ទាប់នៃសារពាង្គកាយកែច្នៃរស់ដូចគ្នា ។

ខ. ហាមឃាត់ការនាំចូល

គ. សំណើសុំព័ត៌មានពាក់ព័ន្ធបន្ថែម អនុលោមទៅតាមក្របខណ្ឌច្បាប់ក្នុងប្រទេសរបស់ខ្លួន ឬឧបសម្ព័ន្ធទី ១ ។ ក្នុងការគណនាពេលវេលាដែលភាគីនាំចូលនឹងត្រូវឆ្លើយតបទៅវិញចំនួនថ្ងៃដែលភាគីត្រូវរង់ចាំទទួលព័ត៌មាន បន្ថែមដែល ទាក់ទងនោះ មិនត្រូវរាប់បញ្ចូលឡើយ ឬ

ឃ. ផ្តល់ព័ត៌មានដល់អ្នកជូនព័ត៌មានថា រយៈពេលដែលបានកំណត់នៅក្នុងកថាខ័ណ្ឌនេះ ត្រូវពន្យាពេលត្រឹម រយៈពេលកំណត់ច្បាស់លាស់ ។

៤. លើកលែងតែក្នុងករណីដែលមានការឯកភាពគ្មានលក្ខខ័ណ្ឌ សេចក្តីសំរេចក្នុងកថាខ័ណ្ឌ ៣ ខាងលើ ត្រូវបញ្ជាក់ពីហេតុផលដោយមានមូលដ្ឋានច្បាស់លាស់ ។

៥. ការខកខានដោយភាគីនាំចូលធ្វើទំនាក់ទំនងពីសេចក្តីសំរេចរបស់ខ្លួនក្នុងរយៈពេល ២៧០ថ្ងៃ នៃកាលបរិច្ឆេទនៃការទទួលសេចក្តីបញ្ជាក់នោះ មិនត្រូវឆ្លុះបញ្ចាំងពីការឯកភាពទៅនឹងចលនាឆ្លងដែនដោយចេតនានោះទេ ។

៦. ការខ្វះភាពច្បាស់លាស់ខាងវិទ្យាសាស្ត្រ ដោយសារតែព័ត៌មាន និងចំណេះដឹងវិទ្យាសាស្ត្រពាក់ព័ន្ធមិនគ្រប់គ្រាន់ទាក់ទងទៅនឹងវិសាលភាពនៃឥទ្ធិពលអវិជ្ជមានរបស់សារពាង្គកាយកែច្នៃរស់មកលើការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនៃជីវៈចំរុះក្នុងប្រទេសភាគីនាំចូល ដោយគិតគូរពីគ្រោះថ្នាក់ដល់សុខភាពមនុស្សផង មិនត្រូវរារាំងភាគីនោះក្នុងការធ្វើសេចក្តីសំរេចសមស្របចំពោះការនាំចូលនៃសារពាង្គកាយកែច្នៃរស់ ក្នុងបញ្ហាដូចបានកំណត់ក្នុងកថាខ័ណ្ឌទី ៣ ខាងលើ ដើម្បីជៀសវាង ឬកាត់បន្ថយអប្បបរមានូវផលប៉ះពាល់អាក្រក់ ។

៧. សន្និសីទភាគីបំរើឱ្យកិច្ចប្រជុំរវាងភាគីទាំងអស់នៅក្នុងកិច្ចប្រជុំដំបូង ត្រូវសំរេចលើបែបបទ និងយន្តការដែលសមស្រប ដើម្បីជួយសំរបសំរួលការធ្វើសេចក្តីសំរេចដោយភាគីនាំចូល ។

## មាត្រាទី ១១

## នីតិវិធីនៃសារពាង្គកាយកែច្នៃរស់ដែលត្រូវបានប្រើប្រាស់ដោយផ្ទាល់ជាអាហារ ចំណីសត្វ ឬសំរាប់ការកែច្នៃ

១. ភាគីដែលធ្វើសេចក្តីសំរេចចុងក្រោយលើការប្រើប្រាស់ក្នុងស្រុក រួមទាំងការដាក់លក់ នៅលើទីផ្សារនូវសារពាង្គកាយកែច្នៃរស់ ដែលអាចពាក់ព័ន្ធនឹងចលនាឆ្លងដែនសំរាប់ការប្រើប្រាស់ដោយផ្ទាល់ជាអាហារ ចំណីសត្វ ឬសំរាប់ការកែច្នៃ ត្រូវជូនព័ត៌មានដល់ភាគីទាំងអស់ តាមរយៈការិយាល័យចែកចាយព័ត៌មានជីវសុវត្ថិភាពក្នុងរយៈពេល ១៥ថ្ងៃ នៃការធ្វើសេចក្តីសំរេចនោះ ។ ព័ត៌មាននេះយ៉ាងហោចណាស់ត្រូវមានព័ត៌មាន ដែលបានកំណត់នៅក្នុងឧបសម្ព័ន្ធទី ២ ។ ភាគីនោះត្រូវផ្តល់ឯកសារចំលងជាលាយលក្ខណ៍អក្សរទៅស្ថាប័នបង្គោលជាតិរបស់ភាគីនីមួយៗ ដែលផ្តល់ព័ត៌មានដល់ លេខាធិការដ្ឋានជាមុនថាខ្លួនពុំអាចទំនាក់ទំនងទៅការិយាល័យចែកចាយព័ត៌មានជីវសុវត្ថិភាពបានឡើយ ។ "ខ" នេះ នឹងមិនអនុវត្តចំពោះសេចក្តីសំរេចណាដែលទាក់ទងទៅនឹងការប្តឹងឡើយ ។

២. ភាគីដែលធ្វើសេចក្តីសំរេចទាក់ទងនឹងកថាខណ្ឌទី ១ ខាងលើ ត្រូវធានាថាមានតំរូវការផ្លូវច្បាប់សំរាប់ភាពត្រឹមត្រូវនៃព័ត៌មានដែលផ្តល់ដោយអ្នកស្នើសុំ ។

៣. ភាគីណាក៏ដោយអាចស្នើសុំព័ត៌មានបន្ថែមពីអជ្ញាធរដូចដែលបានកំណត់នៅក្នុងកថាខ័ណ្ឌ(ខ)ក្នុងឧបសម្ព័ន្ធទី ២ ។

៤. ភាគីណាក៏ដោយអាចធ្វើសេចក្តីសំរេចលើការនាំចូលសារពាង្គកាយកែច្នៃរស់ សំរាប់ប្រើប្រាស់ដោយផ្ទាល់ជាអាហារ ចំណីសត្វ ឬ សំរាប់ការកែច្នៃ នៅក្រោមក្របខ័ណ្ឌច្បាប់ក្នុងស្រុកដែលស្របទៅនឹងគោលបំណងរបស់ពិធីសារនេះ ។

៥. ភាគីនីមួយៗត្រូវផ្តល់ឱ្យការិយាល័យចែកចាយព័ត៌មានជីវសុវត្ថិភាព នូវឯកសារចំលងនៃច្បាប់បរិធានជាតិ និងគោលការណ៍ណែនាំទាំងឡាយដែលអាចអនុវត្តចំពោះចលនាឆ្លងដែននៃសារពាង្គកាយកែច្នៃរស់ សំរាប់ការប្រើប្រាស់ដោយផ្ទាល់ជាអាហារ ចំណីសត្វ ឬ សំរាប់ការកែច្នៃ ។

៦. ភាគីប្រទេសកំពុងអភិវឌ្ឍន៍ ឬភាគីដែលមានវិស័យសេដ្ឋកិច្ចអន្តរកាល ដោយគ្មានក្របខ័ណ្ឌច្បាប់ក្នុងស្រុកស្របទៅនឹងកថាខ័ណ្ឌទី ៤ ខាងលើ និងដោយស្ថិតនៅក្រោមការអនុវត្តន៍នៃដែនសមត្ថកិច្ចរបស់ខ្លួន អាចប្រកាសតាមរយៈ

ការិយាល័យចែកចាយព័ត៌មានជីវសុវត្ថិភាពនូវសេចក្តីសំរេចរបស់ខ្លួន មុនការនាំចូលលើកដំបូងនៃសារពាង្គកាយកែច្នៃរស់ សំរាប់ការប្រើប្រាស់ដោយផ្ទាល់ជាអាហារ ចំណីសត្វ ឬសំរាប់ការកែច្នៃ ដែលព័ត៌មានត្រូវបានផ្តល់អោយនៅក្នុង កថាខណ្ឌទី១ ខាងលើ នឹងត្រូវបានរៀបចំដោយផ្អែកលើ :

ក. ការវាយតំលៃគ្រោះថ្នាក់ ដែលអនុវត្តដោយយោងទៅលើឧបសម្ព័ន្ធទី ៣ និង

ខ. សេចក្តីសំរេចធ្វើឡើងនៅក្នុងពេលវេលាកំណត់មិនលើសពី ២៧០ថ្ងៃ ។

៧. ការខកខានដោយភាគីមិនបានផ្តល់ព័ត៌មាន ស្តីពីសេចក្តីសំរេចរបស់ខ្លួនទៅតាមកថាខណ្ឌទី ៦ ខាងលើ មិនត្រូវបញ្ជាក់ពីការឯកភាព ឬ ការបដិសេធរបស់ខ្លួនចំពោះការនាំចូលនៃសារពាង្គកាយកែច្នៃរស់ មានបំណងសំរាប់ការប្រើប្រាស់ដោយផ្ទាល់ជាអាហារ ចំណីសត្វ ឬសំរាប់ការកែច្នៃ ប្រសិនបើបានបញ្ជាក់ច្បាស់លាស់ដោយភាគីនោះ ។

៨. ការខ្វះភាពច្បាស់លាស់ខាងវិទ្យាសាស្ត្រច្បាស់លាស់ ដោយសារតែចំណេះដឹង និងព័ត៌មានវិទ្យាសាស្ត្រពាក់ព័ន្ធមិនគ្រប់គ្រាន់ទាក់ទងទៅនឹងវិសាលភាពនៃឥទ្ធិពលអវិជ្ជមានរបស់សារពាង្គកាយកែច្នៃរស់លើការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនៃជីវៈចំរុះនៅក្នុងប្រទេសជាភាគីនាំចូល ដោយគិតគូរពីគ្រោះថ្នាក់ដល់សុខភាពមនុស្សផងដែរ មិនត្រូវរារាំងដល់ភាគីនោះក្នុងការធ្វើសេចក្តីសំរេចសមស្របលើការនាំចូលនៃសារពាង្គកាយកែច្នៃរស់ សំរាប់ការប្រើប្រាស់ដោយផ្ទាល់ជាអាហារ ចំណីសត្វ ឬសំរាប់ការកែច្នៃ ដើម្បីជៀសវាង ឬកាត់បន្ថយឱ្យបានអប្បបរមានូវផលប៉ះពាល់អវិជ្ជមាននោះ ។

៩. ភាគីណាក៏ដោយ អាចបង្ហាញនូវតំរូវការជំនួយហិរញ្ញវត្ថុ និងបច្ចេកទេស និងការកសាងសមត្ថភាព ស្តីពីសារពាង្គកាយកែច្នៃរស់ សំរាប់ការប្រើប្រាស់ដោយផ្ទាល់ជាអាហារ ចំណីសត្វ ឬ សំរាប់ការកែច្នៃ ។ ភាគីទាំងអស់ត្រូវសហប្រតិបត្តិការគ្នាដើម្បីឆ្លើយតបទៅនឹងតំរូវការទាំងនេះ ដោយយោងទៅលើមាត្រាទី ២២ និង ២៨។

## មាត្រាទី ១២

## ការត្រួតពិនិត្យសេចក្តីសំរេចឡើងវិញ

១. នៅពេលណាក៏ដោយភាគីនាំចូល បានព័ត៌មានថ្មីអំពីផលប៉ះពាល់អវិជ្ជមានលើការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនៃជីវៈចំរុះ និងដោយគិតគូរពីគ្រោះថ្នាក់ដល់សុខភាពមនុស្សផងនោះ អាចពិនិត្យកែសំរួល និងធ្វើការផ្លាស់ប្តូរសេចក្តីសំរេចទាក់ទងនឹងចលនាឆ្លងដែនដោយចេតនានេះ។ ករណីបែបនេះ ក្នុងរយៈពេល ៣០ថ្ងៃ ភាគីនោះ ត្រូវផ្តល់ព័ត៌មានទៅអ្នកជូនព័ត៌មានដែលបានបញ្ជាក់ពីលើកមុនលើចលនាឆ្លងដែននៃសារពាង្គកាយកែច្នៃរស់នូវសេចក្តីសំរេចនេះ ព្រមទាំងការិយាល័យចែកចាយព័ត៌មានជីវសុវត្ថិភាពផងដែរ ហើយនឹងបង្ហាញពីហេតុផលនៃសេចក្តីសំរេចនេះ ។

២. ភាគីនាំចេញ ឬអ្នកជូនព័ត៌មាន អាចស្នើសុំអោយភាគីនាំចូលធ្វើការពិនិត្យកែសំរួលសេចក្តីសំរេចដែលបានធ្វើឡើងរួច ដោយអនុលោមទៅតាមមាត្រាទី ១០ ដែលភាគីនាំចេញ ឬអ្នកជូនព័ត៌មានពិចារណាថា :

ក. ការផ្លាស់ប្តូរនៅក្នុងកាលៈទេសៈដែលបានកើតឡើងនោះ អាចជះឥទ្ធិពលដល់លទ្ធផលនៃការវាយតំលៃគ្រោះថ្នាក់ ដែលសេចក្តីសំរេចមានមូលដ្ឋានលើ ឬ

ខ. ព័ត៌មានវិទ្យាសាស្ត្រ និងបច្ចេកទេសពាក់ព័ន្ធបន្ថែមនោះអាចយកមកប្រើការបាន ។

៣. ភាគីនាំចូល ត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរចំពោះសំណើបែបនោះនៅក្នុងរយៈពេល ៩០ ថ្ងៃ និងបញ្ជាក់ពីហេតុផលចំពោះសេចក្តីសំរេចចិត្តរបស់ខ្លួន ។

៤. ភាគីនាំចូលដោយមានសេមត្ថកិច្ចក្នុងការសំរេច អាចទាមទារអោយធ្វើការវាយតំលៃគ្រោះថ្នាក់ចំពោះការនាំចូលក្រោយៗទៀត ។

## មាត្រាទី ១៣
## នីតិវិធីសាមញ្ញ

១. ដោយមានតែវិធានការណ៍សមស្របត្រូវបានអនុវត្តដើម្បីធានានូវសុវត្ថិភាពនៃចលនាឆ្លងដែនចេតនា នៃសារពាង្គកាយកែច្នៃរស់អនុលោមទៅតាមគោលបំណងនៃពិធីសារនេះ ភាគីនាំចូលអាចជូនព័ត៌មានជាមុនទៅការិយាល័យចែកចាយព័ត៌មានជីវសុវត្ថិភាព :

ក. ករណីដែលក្នុងនោះចលនាឆ្លងដែនដោយចេតនាទៅភាគីនោះ អាចកើតឡើងស្របពេលដែលចលនានេះត្រូវបានជូនព័ត៌មានទៅភាគីនាំចូលនោះ និង

ខ. ការនាំចូលនៃសារពាង្គកាយកែច្នៃរស់ទៅភាគីនោះ លើកលែងពីបែបបទព្រមព្រៀងជូនព័ត៌មានជាមុន ។ ការជូនព័ត៌មាននៅក្នុងអនុកថាខណ្ឌ (ក) ខាងលើ អាចប្រើចំពោះសកម្មភាពដូចគ្នាក្រោយទៀតទៅលើភាគី ដដែល ។

២. ព័ត៌មាន ដែលទាក់ទងទៅនឹងចលនាឆ្លងដែនដោយចេតនា ដែលនឹងត្រូវផ្តល់អោយក្នុងការជូនព័ត៌មានយោងនឹងកថាខណ្ឌទី ១ ខាងលើ ត្រូវតែជាព័ត៌មានដែលបានបញ្ជាក់ក្នុងឧបសម្ព័ន្ធ ១ ។

## មាត្រាទី ១៤
## ការចាត់ចែង និងកិច្ចព្រមព្រៀងពហុភាគី តំបន់ និងទ្វេភាគី

១. ភាគីទាំងអស់ អាចចុះកិច្ចព្រមព្រៀងទ្វេភាគី តំបន់ និងពហុភាគី និងការរៀបចំចាត់ចែងទាក់ទងទៅនឹងចលនាឆ្លងដែនចេតនានៃសារពាង្គកាយកែច្នៃរស់ ស្របទៅនឹងគោលបំណងនៃពិធីសារនេះ និងកិច្ចព្រមព្រៀង និងការរៀបចំចាត់ចែង ដែលមិនបណ្តាលអោយកំរិតនៃការការពារទាបជាងកំរិតការពារផ្តល់ដោយពិធីសារនេះ ។

២. ភាគីទាំងអស់ត្រូវផ្តល់ព័ត៌មានឱ្យគ្នាទៅវិញទៅមក តាមរយៈការិយាល័យចែកចាយព័ត៌មានជីវសុវត្ថិភាពនូវរាល់កិច្ចព្រមព្រៀងទ្វេភាគី តំបន់ និងពហុភាគី និងការរៀបចំចាត់ចែងដែលភាគីនោះបានធ្វើមុន ឬក្រោយពីកាលបរិច្ឆេទនៃការចូលជាធរមានរបស់ពិធីសារនេះ ។

៣. " ខ " នៃពិធីសារនេះ នឹងមិនប៉ះពាល់ដល់ចលនាឆ្លងដែនចេតនា ដោយអនុលោមទៅតាមកិច្ចព្រមព្រៀង និងការរៀបចំចាត់ចែងដែលធ្វើឡើងរវាងភាគីនៃកិច្ចព្រមព្រៀង ឬការរៀបចំចាត់ចែងទាំងនោះទេ ។

៤. ភាគីទាំងឡាយ អាចកំណត់ថាច្បាប់ប្រទេសរបស់ខ្លួន ត្រូវអនុវត្តដោយអនុលោមទៅតាមការនាំចូលជាក់ស្តែងទៅក្នុងប្រទេសនោះ ហើយត្រូវជូនព័ត៌មានទៅការិយាល័យចែកចាយព័ត៌មានជីវសុវត្ថិភាព អំពីសេចក្តីសំរេចរបស់ខ្លួន ។

## មាត្រាទី ១៥
## ការវាយតំលៃពីគ្រោះថ្នាក់

១. ការវាយតំលៃគ្រោះថ្នាក់ ដែលបានអនុវត្តដោយអនុលោមទៅតាមពិធីសារនេះ ត្រូវរៀបចំធ្វើឡើងក្នុងគោលដៅវិទ្យាសាស្ត្រ ដោយអនុលោមតាមឧបសម្ព័ន្ធទី ៣ និងត្រូវគិតគូរពីបច្ចេកទេសវាយតំលៃគ្រោះថ្នាក់ ។ ការវាយតំលៃគ្រោះថ្នាក់បែបនេះ ត្រូវផ្អែកលើព័ត៌មានដែលបានចែងនៅក្នុងមាត្រាទី ៨ និងភស្តុតាងវិទ្យាសាស្ត្រដែលអាច យកជាការបានផ្សេងទៀតដើម្បីវាយតំលៃពីផលប៉ះពាល់អវិជ្ជមាននៃសារពាង្គកាយរស់ដែលកែច្នៃ ទៅលើការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនៃជីវៈចំរុះ ព្រមទាំងគិតគូរពីគ្រោះថ្នាក់ទៅលើសុខភាពមនុស្សផងដែរ ។

២. ភាគីនាំចូលត្រូវធានាថា ការវាយតំលៃគ្រោះថ្នាក់ត្រូវបានអនុវត្តចំពោះសេចក្តីសំរេច នៅក្នុងមាត្រា ទី ១០ ។ ភាគីនេះអាចទាមទារអោយអ្នកនាំចេញអនុវត្តនូវការវាយតំលៃគ្រោះថ្នាក់នេះ ។

៣. ការចំណាយនៃការវាយតំលៃគ្រោះថ្នាក់ ត្រូវចេញដោយអ្នកជូនព័ត៌មានប្រសិនបើភាគីចូលទាមទារដូច្នេះ ។

## មាត្រាទី ១៦

## ការគ្រប់គ្រងគ្រោះថ្នាក់

១. ភាគីទាំងអស់ ដោយផ្អែកលើមាត្រាទី ៨ (g)នៃអនុសញ្ញានេះ ត្រូវបង្កើត និងរក្សានូវយន្តការ វិធានការណ៍ និងយុទ្ធសាស្រ្តសមស្រប ដើម្បីគ្រប់គ្រង និងត្រួតពិនិត្យគ្រោះថ្នាក់ដែលបានកំណត់នៅក្នុង " ឧ " នៃការវាយតំលៃគ្រោះថ្នាក់របស់ពិធីសារនេះ ទាក់ទងនឹងការប្រើប្រាស់ ការគ្រប់គ្រង និងចលនាឆ្លងដែននៃសារពាង្គកាយកែច្នៃរស់ ។

២. វិធានការណ៍ផ្អែកលើការវាយតំលៃគ្រោះថ្នាក់ត្រូវបានដាក់កំហិតដើម្បីទប់ស្កាត់ផលប៉ះពាល់អាក្រក់នៃសារពាង្គកាយកែច្នៃរស់ ទៅលើការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តភាពនៃជីវៈចំរុះ ដោយគិតគូរផងដែរពីគ្រោះថ្នាក់ទៅលើសុខភាពមនុស្សនៅក្នុងទឹកដីនៃភាគីនាំចូល ។

៣. ភាគីនីមួយៗ ត្រូវចាត់វិធានការណ៍អោយបានសមស្របដើម្បីទប់ស្កាត់សកម្មភាពឆ្លងដែនអចេតនានៃសារពាង្គកាយកែច្នៃរស់ រួមទាំងវិធានការណ៍តំរូវអោយមានការវាយតំលៃគ្រោះថ្នាក់ដែលនឹងត្រូវអនុវត្តឱ្យបានមុនអនុញ្ញាតឱ្យបញ្ចេញលើកដំបូងនូវសារពាង្គកាយកែច្នៃរស់ ។

៤. ដោយមិនពាក់ព័ន្ធទៅនឹងកថាខ័ណ្ឌទី ២ ខាងលើ ភាគីនីមួយៗ ត្រូវខិតខំប្រឹងដើម្បីធានាថាសារពាង្គកាយកែច្នៃរស់ ទោះជាត្រូវបាននាំចូល ឬអភិវឌ្ឍន៍ក្នុងស្រុកក៏ដោយ បានដាក់ឱ្យឆ្លងកាត់រយៈពេលនៃការត្រួតពិនិត្យយ៉ាងម៉ត់ចត់ដែលស្មើគ្នាទៅនឹងវដ្តនៃជីវិត ឬរយៈពេលនៃការផលិត មុនពេលដាក់ប្រើប្រាស់ ។

៥. ភាគីទាំងឡាយត្រូវសហប្រតិបត្តិការដើម្បី :

ក. កំណត់សារពាង្គកាយកែច្នៃរស់ ឬកំណត់លក្ខណៈពិសេសនៃសារពាង្គកាយកែច្នៃរស់ ដែលអាចបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានទៅលើការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនៃជីវៈចំរុះ ព្រមទាំងគិតគូរពីគ្រោះថ្នាក់ដល់ សុខភាពមនុស្សផងដែរ ។

ខ. ចាត់វិធានការណ៍អោយបានសមស្រប ដែលទាក់ទងទៅនឹងការថែរក្សានៃសារពាង្គកាយកែច្នៃរស់ ឬលក្ខណៈពិសេសរបស់វា ។

## មាត្រាទី ១៧

## ចលនាឆ្លងដែនអចេតនា និងវិធានការណ៍បន្ទាន់

១. ភាគីនីមួយៗ ត្រូវចាត់វិធានការណ៍អោយបានសមស្រប ដើម្បីជូនព័ត៌មានដល់ប្រទេសរងគ្រោះ និងប្រទេសទទួលរងគ្រោះខ្លាំង ការិយាល័យចែកចាយព័ត៌មានជីវសុវត្ថិភាព និងអង្គការអន្តជាតិដែលពាក់ព័ន្ធ នៅពេលទទួលដំណឹងពីការកើតឡើងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដែលនាំឱ្យ ឬអាចនាំអោយមានចលនាឆ្លងដែនដោយអចេតនានៃសារពាង្គកាយកែច្នៃរស់ ដែលទំនងជាមានផលប៉ះពាល់យ៉ាងខ្លាំងដល់ការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនៃជីវៈចំរុះ ព្រមទាំងគិតគូរពីគ្រោះថ្នាក់ដល់សុខភាពមនុស្សនៃប្រទេសនោះផងដែរ ។

២. ភាគីនីមួយៗ ត្រូវជូនព័ត៌មានទៅការិយាល័យចែកចាយព័ត៌មានជីវសុវត្ថិភាព មិនយឺតជាងកាលបរិច្ឆេទនៃការចូលជាធរមាននៃភាគីនោះក្នុងពិធីសារនេះ នូវព័ត៌មានលំអិតដែលពាក់ពន្ធ័ ដែលកំណត់អាស័យដ្ឋានទំនាក់ទំនងដើម្បីទទួលព័ត៌មានចែងក្នុងមាត្រានេះ ។

៣. ព័ត៌មានទាំងឡាយ ដែលមាននៅក្នុងកថាខណ្ឌទី ១ ខាងលើនេះរួមបញ្ចូល :

ក. ព័ត៌មានទាក់ទងដែលអាចទទួលបាន ស្តីពីបរិមាណវាយតំលៃរួច និងបុគ្គលិកលក្ខណៈនៃសារពាង្គកាយកែច្នៃរស់ ។

ខ. ព័ត៌មានស្តីពីកាលៈទេសៈ និងកាលបរិច្ឆេតសំរាប់ការបញ្ចេញ និងការប្រើប្រាស់នៃសារពាង្គកាយកែច្នៃរស់នៅក្នុងភាគីជាដើមកំណើតនៃសារពាង្គកាយនោះ ។

គ. ព័ត៌មានដែលអាចទទួលបាន អំពីផលប៉ះពាល់អវិជ្ជមានលើការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនៃជីវៈចំរុះ និងគិតគូរពីគ្រោះថ្នាក់ដល់សុខភាពមនុស្សផងដែរ ព្រមទាំងព័ត៌មានស្តីពីវិធានការណ៍គ្រប់គ្រងគ្រោះថ្នាក់ដែលអាចកើតមានឡើង ។

ឃ. ព័ត៌មានពាក់ព័ន្ធផ្សេងទៀត និង

ង. អាស័យដ្ឋានទំនាក់ទំនងសំរាប់ព័ត៌មានបន្ថែម ។

៤. ដើម្បីកាត់បន្ថយជាអប្បបរមានូវផលប៉ះពាល់អាក្រក់លើការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តភាពនៃជីវចំរុះដោយគិតគូរពីគ្រោះថ្នាក់ដល់សុខភាពមនុស្សផងដែរ ភាគីនីមួយៗដែលនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន នៅពេលការបញ្ចេញនូវសារពាង្គកាយកែច្នៃរស់យោងទៅលើកថាខណ្ឌទី ១ ខាងលើ កើតមានឡើង ត្រូវពិគ្រោះយោបល់ជាបន្ទាន់ជាមួយប្រទេសដែលទទួលរងនូវការប៉ះពាល់ ឬប្រទេសដែលទទួលរងនូវការប៉ះពាល់ខ្លាំង ដើម្បីជំរុញឱ្យភាគីទាំងនោះធ្វើការកំណត់នូវដំណោះស្រាយ និងផ្តួចផ្តើមសកម្មភាពចាំបាច់ រួមទាំងវិធានការណ៍បន្ទាន់ ។

## មាត្រាទី ១៨

## ការគ្រប់គ្រង ការដឹកជញ្ជូន ការវេចខ្ចប់ និងអត្តសញ្ញាណកម្ម

១. ដើម្បីចៀសវាងផលប៉ះពាល់ផ្សេងៗទៅលើការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនៃជីវៈចំរុះ ដោយគិតគូរពីគ្រោះថ្នាក់ដល់សុខភាពមនុស្សផងដែរ ភាគីនីមួយៗត្រូវចាត់វិធានការណ៍ចាំបាច់ដើម្បីតំរូវអោយសារពាង្គកាយកែច្នៃរស់ ដោយគោរពទៅនឹងចលនាឆ្លងដែនចេតនានៅក្នុងវិសាលភាពនៃពិធីសារនេះត្រូវបានគ្រប់គ្រង វេចខ្ចប់ និងដឹកជញ្ជូនអោយមានសុវត្ថិភាពដោយគិតគូរទៅលើច្បាប់ និងបទដ្ឋានអន្តរជាតិដែលពាក់ព័ន្ធ ។

២. ភាគីនីមួយៗត្រូវចាត់វិធានការណ៍ផ្សេងៗ ដើម្បីតំរូវអោយមានឯកសារ ស្តីពីៈ

ក. សារពាង្គកាយកែច្នៃរស់ដែលសំរាប់ប្រើប្រាស់ដោយផ្ទាល់ជាអាហារ ចំណីសត្វ ឬសំរាប់ការកែច្នៃ ត្រូវកំណត់ឱ្យយ៉ាងច្បាស់ថាសារពាង្គកាយទាំងនោះអាចផ្ទុកសារពាង្គកាយកែច្នៃរស់ និងមិនត្រូវបានអោយនាំចូលដោយចេតនាទៅក្នុង បរិស្ថាន ព្រមទាំងអាស័យដ្ឋានទំនាក់ទំនងសំរាប់ព័ត៌មានបន្ថែម ។ សន្និសីទភាគីបំរើជាកិច្ចប្រជុំរវាងភាគីចុះកិច្ចសន្យា ទៅនឹងពិធីសារនេះ ត្រូវធ្វើសេចក្តីសំរេចទៅលើតំរូវការលំអិតសំរាប់គោលបំណងនេះ រួមទាំងការបញ្ជាក់យ៉ាងច្បាស់ពីអិនភាព និងអិនភាពប្លែកៗ របស់សារពាង្គកាយទាំងនេះ មិនយឺតជាង ២ ឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទនៃការចូលជាធរមានទៅក្នុង ពិធីសារនេះ ។

ខ. សារពាង្គកាយកែច្នៃរស់ដែលមានទិសដៅសំរាប់ការប្រើប្រាស់ដោយមានកំរិត ត្រូវកំណត់អោយបានច្បាស់លាស់ថា វាពិតជាសារពាង្គកាយកែច្នៃរស់ និងត្រូវបញ្ជាក់ពីតំរូវការផ្សេងៗសំរាប់ការគ្រប់គ្រង ការផ្ទុក ការដឹកជញ្ជូន និង ការប្រើប្រាស់ដោយសុវត្ថិភាព រួមទាំងអាស័យដ្ឋានទំនាក់ទំនងសំរាប់ព័ត៌មានបន្ថែម នៃបុគ្គល និងស្ថាប័នដែលទទួលខុសត្រូវ លើបញ្ហាសារពាង្គកាយកែច្នៃរស់នេះ ។

គ. សារពាង្គកាយកែច្នៃរស់ដែលត្រូវបានគេគ្រោងទុកសំរាប់នាំចូលដោយចេតនាទៅក្នុងបរិស្ថាន នៃភាគីនាំចូល និងសារពាង្គកាយកែច្នៃរស់ផ្សេងទៀតនៅក្នុងវិសាលភាពនៃពិធីសារនេះត្រូវធ្វើអត្តសញ្ញាណកម្មអោយយ៉ាងច្បាស់លាស់ ក្នុងនាមសារពាង្គកាយកែច្នៃរស់ ត្រូវបញ្ជាក់ពីភិនភាគ និងបុគ្គលិកលក្ខណៈពិសេសៗ តំរូវការនានាសំរាប់ការគ្រប់គ្រង ការផ្ទុក ការដឹកជញ្ជូន និងការប្រើប្រាស់ដោយសុវត្ថិភាព អាស័យដ្ឋានទំនាក់ទំនងសំរាប់ព័ត៌មានបន្ថែម និងឈ្មោះនិងអាស័យដ្ឋាន នៃអ្នកនាំចេញ និងអ្នកនាំចូល ដោយមានការបញ្ជាក់ពីចលនានេះគឺស្របទៅនឹងតំរូវការនៃពិធីសារនេះដែលអនុវត្តចំពោះ អ្នកនាំចេញ ។

៣. សន្និសីទភាគីបំរើជាកិច្ចប្រជុំរវាងភាគីចុះកិច្ចសន្យាទៅនឹងពិធីសារនេះ ត្រូវពិចារណាដល់សេចក្តីត្រូវការ និងតំរូវ នៃបទដ្ឋានទាក់ទងនឹងការធ្វើអត្តសញ្ញាណកម្ម ការគ្រប់គ្រង ការវិចខ្ចប់ និងការដឹកជញ្ជូន ដោយធ្វើការពិគ្រោះយោបល់ ជាមួយនឹងអង្គការអន្តរជាតិពាក់ព័ន្ធ ។

## មាត្រាទី ១៩

## អជ្ញាធរសមត្ថកិច្ចជាតិ និងស្ថាប័នបង្គោលជាតិ

១. ភាគីនីមួយៗ ត្រូវតែងតាំងបុគ្គលបង្គោលជាតិមួយរូប (National Focal Point) ដែលទទួលខុសត្រូវការងារទំនាក់ទំនងជាមួយលេខាធិការដ្ឋានជួសមុខឱ្យភាគីរបស់ខ្លួន ។ ភាគីនីមួយៗ ត្រូវតែងតាំងផងដែរនូវអជ្ញាធរសមត្ថកិច្ចជាតិមួយ ឬច្រើនដែលទទួលខុសត្រូវក្នុងមុខងាររដ្ឋបាលដែលកំណត់ដោយពិធីសារនេះ និងដែលមានអំនាចជំនួសមុខឱ្យភាគីរបស់ខ្លួន ដោយគោរពទៅតាមមុខងារទាំងនោះ ។ ភាគីអាចតែងតាំងអង្គភាពតែមួយ ដើម្បីបំពេញមុខងារទាំងបុគ្គលបង្គោល និង អជ្ញាធរសមត្ថកិច្ចជាតិ ។

២. ភាគីនីមួយៗ ត្រូវជូនដំណឹងទៅលេខាធិការដ្ឋាននូវឈ្មោះ និងអាស័យដ្ឋានរបស់បុគ្គលបង្គោល និងអជ្ញាធរសមត្ថកិច្ចជាតិ មិនអោយហួសពីកាលបរិច្ឆេតនៃការចូលជាធរមាននៃពិធីសារនេះទេ ។ ភាគីដែលតែងតាំងអជ្ញាធរសមត្ថកិច្ចជាតិលើសពីមួយ ភាគីនោះត្រូវបង្ហាញដល់លេខាធិការដ្ឋាននូវព័ត៌មានដែលទាក់ទងទៅនឹងការទទួលខុសត្រូវ នៃអជ្ញាធរទាំងនោះ ។ នៅទីណាដែលអាចអនុវត្តបាន ព័ត៌មានបែបនេះត្រូវបញ្ជាក់តិចបំផុតដល់អជ្ញាធរទទួលខុសត្រូវចំពោះប្រភេទនៃសារពាង្គកាយកែច្នៃរស់ ។ ភាគីនីមួយៗត្រូវបញ្ជាក់ភ្លាមដល់លេខាធិការដ្ឋាននូវការផ្លាស់ប្តូរក្នុងការតែងតាំងបុគ្គលបង្គោលជាតិ ឬ ឈ្មោះ និងអាស័យដ្ឋាន ឬ ការទទួលខុសត្រូវរបស់អជ្ញាធរ សមត្ថកិច្ចជាតិ ។

៣. លេខាធិការដ្ឋាន ត្រូវផ្តល់ព័ត៌មាននិងជូនដំណឹងជាបន្ទាន់ទៅភាគីទាំងឡាយ នូវព័ត៌មានដែលគេទទួលបាន ដូចមានចែងក្នុងកថាខ័ណ្ឌ ២ ខាងលើ ព្រមទាំងផ្តល់ព័ត៌មានបែបនេះទៅការិយាល័យជីវសុវត្ថិភាព ។

## មាត្រាទី ២០

## ការចែកចាយព័ត៌មាន និងការិយាល័យចែកចាយព័ត៌មានជីវសុវត្ថិភាព

១. ការិយាល័យចែកចាយព័ត៌មានជីវសុវត្ថិភាព ត្រូវបានបង្កើតឡើងជាផ្នែកមួយនៃយន្តការផ្សព្វផ្សាយព័ត៌មាន ក្នុងមាត្រាទី ១៨ កថាខ័ណ្ឌ ៣ នៃអនុសញ្ញានេះដើម្បី :

ក. ជួយសម្រួលការដោះដូរព័ត៌មានវិទ្យាសាស្ត្រ បច្ចេកទេស បរិស្ថាន និងច្បាប់ និងបទពិសោធន៍ ស្តីពីសារពាង្គកាយកែច្នៃរស់ ។

ខ. ជួយដល់ភាគីក្នុងការអនុវត្តន៍ពិធីសារនេះ ដោយគិតគូរដល់តំរូវការពិសេសនៃភាគីប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសប្រទេសដែលមានការអភិវឌ្ឍន៍តិចបំផុត និងប្រទេសកំពុងអភិវឌ្ឍន៍ជាកោះតូចៗ និងប្រទេសមានសេដ្ឋកិច្ច អន្តរកាល ក៏ដូចជាប្រទេសដែលជាប្រភពដើម និងជាមណ្ឌលប្រមូលផ្តុំសេនេទិចចំរុះ ។

២. ការិយាល័យចែកចាយព័ត៌មានជីវសុវត្ថិភាព ត្រូវបំរើជាមធ្យោបាយដែលក្នុងការផ្តល់ព័ត៌មានអាចធ្វើឡើងបាន សំរាប់គោលបំណងនៃកថាខ័ណ្ឌទី១ ខាងលើ។ ការិយាល័យចែកចាយព័ត៌មាននឹងផ្តល់ព័ត៌មានយ៉ាងទូលាយដល់ភាគីពាក់ព័ន្ធ នឹងការអនុវត្តន៍ពិធីសារនេះ។ វាក៏ផ្តល់ផងដែរនូវយន្តការក្នុងការផ្លាស់ប្តូរ ព័ត៌មានជីវសុត្ថិភាពអន្តរជាតិផ្សេងទៀត ។

៣. ដោយពុំមានការទាក់ទងទៅនឹងកិច្ចការពារនៃព័ត៌មានសម្ងាត់ ភាគីនីមួយៗត្រូវផ្តល់ព័ត៌មានទៅក្នុងការិយាល័យចែកចាយព័ត៌មានជីវសុវត្ថិភាព នូវព័ត៌មានណាដែលចាំបាច់សំរាប់ការិយាល័យចែកចាយព័ត៌មានជីវសុវត្ថិភាពនៅក្នុងពិធីសារនេះ ព្រមទាំង :

ក. ច្បាប់ បទដ្ឋាន គោលការណ៍ណែនាំដែលមានស្រាប់ សំរាប់ការអនុវត្តន៍ពិធីសារនេះ ព្រមទាំងព័ត៌មានដែលជាតំរូវការដោយភាគីទាំងនោះ សំរាប់បែបបទព្រមព្រៀងជូនព័ត៌មានជាមុន ។

ខ. កិច្ចព្រមព្រៀង និងការរៀបចំចាត់ចែងទ្វេរភាគី តំបន់ និងពហុភាគី

គ. សេចក្តីសង្ខេបនៃការវាយតំលៃពីគ្រោះថ្នាក់ ឬ ការវាយតំលៃបរិស្ថាននៃសារពាង្គកាយកែច្នៃរស់ ដែលអនុវត្តដោយដំណើរការខាងច្បាប់របស់ខ្លួន និងអនុវត្តដោយយោងទៅលើមាត្រាទី ១៥ រួមមានព័ត៌មានពាក់ព័ន្ធស្តីពី ផលិតផលជាសារធាតុកែច្នៃ ដែលមានប្រភពដើមជាសារពាង្គកាយកែច្នៃរស់ផ្ទុកនូវសារធាតុផ្សំរកឃើញថ្មី នៃ សំភារៈសេនេទិចដែលទទួលបានពីការប្រើប្រាស់ជីវបច្ចេកវិទ្យាទំនើប ។

ឃ. សេចក្តីសំរេចចុងក្រោយទាក់ទងនឹងការនាំចេញ និងការបញ្ចេញនូវសារពាង្គកាយកែច្នៃរស់ ។

ង. របាយការណ៍ដែលត្រូវបានផ្តល់ឱ្យដោយយោងទៅតាមមាត្រាទី ៣៣ រួមបញ្ចូលរបាយការណ៍ ស្តីពីការអនុវត្តន៍បែបបទព្រមព្រៀងជូនព័ត៌មានជាមុន ។

៤. តំរូវនៃការប្រតិបត្តិរបស់ការិយាល័យចែកចាយព័ត៌មានជីវសុវត្ថិភាព រួមបញ្ចូលរបាយការណ៍ស្តីពីសកម្មភាពរបស់ខ្លួន ត្រូវតែយកមកពិចារណា និងសំរេចដោយយោលទៅលើសន្និសីទភាគីដែលជាកិច្ចប្រជុំរវាងភាគីចុះកិច្ចសន្យាទៅនឹងពិធីសារនេះ នៅក្នុងកិច្ចប្រជុំដំបូង ហើយត្រូវបានបន្តត្រួតពិនិត្យឡើងវិញបន្ទាប់ពីនោះ ។

## មាត្រាទី ២១

## ព័ត៌មានសំងាត់

១. ភាគីនាំចូល ត្រូវអនុញ្ញាតអោយអ្នកជូនព័ត៌មាន ដើម្បីកំណត់នូវព័ត៌មានដែលផ្តល់ជូន នៅក្រោមបែបបទនៃពិធីសារនេះ ឬត្រូវការដោយភាគីនាំចូលជាផ្នែកមួយនៃបែបបទព្រមព្រៀងជូនព័ត៌មានជាមុន របស់ពិធីសារ ដែលត្រូវរក្សាឱ្យបានសំងាត់។ ការបញ្ជាក់ពិហេតុផលត្រូវផ្តល់ជូនក្នុងករណីនោះ ប្រសិនបើមានសំណើ ។

២. ភាគីនាំចូល ត្រូវពិគ្រោះយោបល់ជាមួយអ្នកជូនព័ត៌មាន ប្រសិនបើភាគីនោះសំរេចថាព័ត៌មានដែលកំណត់ដោយអ្នកជូនព័ត៌មានជាឯកសារសំងាត់ លាក់ការ គឺមិនមានលក្ខណៈជាឯកសារលាក់ការ ហើយភាគីនោះត្រូវផ្តល់ដំណឹងដល់អ្នកជូនព័ត៌មាននូវសេចក្តីសំរេចរបស់ខ្លួនមុនធ្វើការផ្សព្វផ្សាយ ដោយផ្តល់នូវហេតុផលទៅលើសំណើ ព្រមទាំងឱកាសសំរាប់ពិគ្រោះយោបល់ និងពិនិត្យឡើងវិញនូវសេចក្តីសំរេចមុននឹងធ្វើការផ្សព្វផ្សាយ ។

៣. ភាគីនីមួយៗ ត្រូវរក្សានូវព័ត៌មានលាក់ការដែលទទួលបាននៅក្នុងពិធីសារនេះ រួមបញ្ចូលព័ត៌មានលាក់ការដែលបានទទួលនៅក្នុងបរិបទនៃបែបបទព្រមព្រៀងជូនព័ត៌មានជាមុនរបស់ពិធីសារនេះ ។ ភាគីនីមួយៗត្រូវធានាថាខ្លួនមានបែបបទដើម្បីរក្សាព័ត៌មានបែបនោះ និងត្រូវការពារព័ត៌មានលាក់ការនេះក្នុងគោលបំណងរក្សាព័ត៌មានសំងាត់ទាក់ទងនឹងសារពាង្គកាយកែច្នៃរស់ក្នុងស្រុក ។

៤. ភាគីនាំចូល មិនត្រូវប្រើប្រាស់ព័ត៌មាននោះសំរាប់គោលបំណងពាណិជ្ជកម្មទេ លើកលែងតែមានការឯកភាពជាលាយល័ក្ខអក្សរពីអ្នកជូនព័ត៌មាន ។

៥.. ប្រសិនបើអ្នកជូនព័ត៌មានដកចេញ ឬបានដកចេញនូវព័ត៌មាននេះ ភាគីនាំចូលត្រូវគោរពនូវការសំងាត់នៃព័ត៌មានពាណិជ្ជកម្ម និងឧស្សាហកម្ម រួមទាំងព័ត៌មាននៃការស្រាវជ្រាវ និងការអភិវឌ្ឍន៍ ក៏ដូចជាព័ត៌មានដែលភាគីនោះ និងអ្នកជូនព័ត៌មានមិនយល់ស្របថាជាការសំងាត់របស់ខ្លួន ។

៦. ដោយមិនទាក់ទងនឹងកថាខ័ណ្ឌទី៥ខាងលើនេះព័ត៌មានខាងក្រោមនេះមិនត្រូវបានចាត់ទុកជាព័ត៌មានលាក់ការទេ :

ក. ឈ្មោះ និងអាស័យដ្ឋានអ្នកជូនព័ត៌មាន

ខ. ការពណ៌នាទូទៅលើសារពាង្គកាយរស់ និងសារពាង្គកាយកែច្នៃរស់

គ. សេចក្តីសង្ខេបនៃការវាយតំលៃគ្រោះថ្នាក់លើការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនៃជីវៈចំរុះដោយគិតគូរដល់គ្រោះថ្នាក់នៃសុខភាពមនុស្សផងដែរ និង

ឃ. វិធីសាស្ត្រ និងផែនការសំរាប់ឆ្លើយតបនឹងគ្រោះអាសន្ន ។

## មាត្រាទី ២២

## ការកសាងសមត្ថភាព

១. ភាគីដែលចុះកិច្ចសន្យា ត្រូវធ្វើសហប្រតិបត្តិការការក្នុងការអភិវឌ្ឍន៍ និងពង្រឹងធនធានមនុស្ស និងសមត្ថភាពស្ថាប័នក្នុងវិស័យជីវសុវត្ថិភាព រួមទាំងជីវបច្ចេកវិទ្យាដែលត្រូវការសំរាប់ជីវសុវត្ថិភាព សំរាប់គោលបំណងនៃការអនុវត្តន៍ពិធីសារនេះអោយមានប្រសិទ្ធិភាព នៅក្នុងភាគីប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេស ប្រទេសមានការអភិវឌ្ឍន៍តិចបំផុត និងប្រទេសកំពុងអភិវឌ្ឍន៍ដែលជាកោះតូចៗ និងប្រទេសមានសេដ្ឋកិច្ចអន្តរកាលតាមរយៈស្ថាប័ន និងអង្គការថ្នាក់ពិភពលោក តំបន់ អនុតំបន់ និងជាតិ និងតាមរយៈការជួយសម្រួលការចូលរួមរបស់ផ្នែកឯកជន ។

២. ចំពោះគោលបំណងនៃការអនុវត្តនីកថាខ័ណ្ឌទី ១ ខាងលើ ទាក់ទងទៅនឹងកិច្ចសហប្រតិបត្តិការតំរូវការនៃភាគីប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសប្រទេសមានការអភិវឌ្ឍន៍តិចបំផុត ប្រទេសកំពុងអភិវឌ្ឍន៍កោះតូចៗ និងប្រទេសមានសេដ្ឋកិច្ចអន្តរកាលចំពោះធនធានហិរញ្ញវត្ថុ និងសិទ្ធិប្រើប្រាស់និងការផ្ទេរបច្ចេកវិទ្យា និងវិធីសាស្ត្រយោងទៅនឹង " ខ " ពាក់ព័ន្ធទៅនឹងអនុសញ្ញានេះ ត្រូវគិតគូរអោយបានពេញលេញសំរាប់ការកសាងសមត្ថភាពខាងជីវសុវត្ថិភាព ។ កិច្ចសហប្រតិបត្តិការទាក់ទងទៅនឹងស្ថានភាពខុសៗគ្នា សមត្ថភាព និងតំរូវការនៃភាគីនីមួយៗ បញ្ចូលការបណ្តុះបណ្តាលវិទ្យាសាស្ត្រ និងបច្ចេកទេសលើការគ្រប់គ្រងជីវបច្ចេកវិទ្យាឱ្យសមស្រប និងមានសុវត្ថិភាព ព្រមទាំងការប្រើប្រាស់នៃការវាយតំលៃគ្រោះថ្នាក់ និងការគ្រប់គ្រងគ្រោះថ្នាក់សំរាប់ជីវសុវត្ថិភាព ហើយលើការបង្កើនសមត្ថភាពស្ថាប័ន និងបច្ចេកវិទ្យានៃជីវសុវត្ថិភាព ។ តំរូវការនៃភាគីដែលមានសេដ្ឋកិច្ចអន្តរកាល ត្រូវគិតគូរយ៉ាងម៉ឺតចត់ចំពោះការកសាងសមត្ថភាពបែបនេះលើជីវសុវត្ថិភាព ។

## មាត្រាទី ២៣
## ការចូលរួម និងការយល់ដឹងសាធារណៈ

១. ភាគីចុះកិច្ចសន្យាត្រូវ:

ក. ជំរុញ និងជួយសម្រួលការចូលរួម ការអប់រំ ការយល់ដឹងសាធារណៈ ពាក់ព័ន្ធទៅនឹងការផ្ទេរ ការគ្រប់គ្រង និងការប្រើប្រាស់ដោយសុវត្ថិភាពនូវសារពាង្គកាយកែច្នៃរស់ទាក់ទងទៅនឹងការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនៃ ជីវៈចំរុះ ហើយត្រូវគិតគូរផងដែរដល់គ្រោះថ្នាក់នៃសុខភាពមនុស្ស ។ ក្នុងអត្ថន័យនេះ ភាគីទាំងនេះត្រូវសហការឱ្យបាន សមស្របជាមួយប្រទេស និងអង្គការអន្តរជាតិផ្សេងទៀត ។

ខ. ខំប្រឹងប្រែងឱ្យអស់លទ្ធភាពដើម្បីធានាថាការអប់រំ និងការយល់ដឹងសាធារណៈគ្របដណ្តប់សិទ្ធប្រើប្រាស់ព័ត៌មានស្តីពីសារពាង្គកាយកែច្នៃរស់ ដែលបានធ្វើអត្តសញ្ញាណកម្មដោយយោលទៅតាមពិធីសារនេះ ដែលអាចអនុញ្ញាតឱ្យនាំចូល ។

២. យោលទៅលើច្បាប់ បរិបទរបស់ប្រទេសនីមួយៗ ភាគីចុះកិច្ចសន្យាត្រូវពិគ្រោះយោបល់សាធារណៈពីដំណើរការនៃការធ្វើសេចក្តីសំរេចដែលទាក់ទងនឹងសារពាង្គកាយកែច្នៃរស់ និង ប្រកាសលទ្ធផលនៃសេចក្តីសំរេចនោះ ដល់សាធារណៈដោយគោរពទៅតាមព័ត៌មានលាក់ការដូចមានចែងក្នុងមាត្រាទី ២១ ។

៣. ភាគីនីមួយៗ ត្រូវខំប្រឹងប្រែងជូនដំណឹងដល់សាធារណៈ អំពីមធ្យោបាយទូទៅដែលអាចទំនាក់ទំនងទៅការិយាល័យចែកចាយព័ត៌មានជីវសុវត្ថិភាព ។

## មាត្រាទី ២៤
## ភាគីដែលមិនទាន់ចុះកិច្ចសន្យា

១. ចលនាឆ្លងដែននៃសារពាង្គកាយកែច្នៃរស់ រវាងភាគីចុះកិច្ចសន្យា និងភាគីមិនទាន់ចុះកិច្ចសន្យា ត្រូវគោរពទៅតាមគោលបំណងនៃពិធីសារនេះ ។ ភាគីចុះកិច្ចសន្យានេះ អាចចុះកិច្ចព្រមព្រៀង និងកិច្ចរៀបចំចាត់ចែងពហុភាគី តំបន់ និងទ្វេភាគី ជាមួយនឹងភាគីមិនទាន់ចុះកិច្ចសន្យា អំពីចលនាឆ្លងដែន ។

២. ភាគីចុះកិច្ចសន្យា ត្រូវជំរុញដល់ភាគីដែលមិនទាន់ចុះកិច្ចសន្យាអោយផ្តល់ការគាំទ្រចំពោះពិធីសារនេះ និងផ្តល់វិភាគទានព័ត៌មានសមស្រប ដល់ការិយាល័យចែកចាយព័ត៌មានជីវសុវត្ថិភាពស្តីពីសារពាង្គកាយកែច្នៃរស់ដែលត្រូវបានបញ្ចេញ ឬនាំចូលទៅក្នុង ឬនាំចេញទៅក្រៅតំបន់ ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចជាតិរបស់ខ្លួន ។

## មាត្រាទី ២៥

## ចលនាឆ្លងដែនខុសច្បាប់

១. ប្រសិនបើសមស្រប ភាគីនីមួយៗត្រូវអនុម័តវិធានការក្នុងស្រុកសមស្របដែលមានគោលដៅការពារ និងផាកពិន័យលើចលនាឆ្លងដែននៃសារពាង្គកាយកែច្នៃរស់ដែលអនុវត្តផ្ទុយទៅនឹងវិធានការក្នុងស្រុករបស់ខ្លួន ។ ចលនាបែបនេះត្រូវបានចាត់ទុកថាជាចលនាឆ្លងដែនខុសច្បាប់ ។

២. ក្នុងករណីដែលមានចលនាឆ្លងដែនខុសច្បាប់ ភាគីទទួលផលប៉ះពាល់អាចស្នើសុំអោយភាគីនាំចូល បង់ថ្លៃខូចខាតទៅលើសារពាង្គកាយកែច្នៃរស់ ដោយចោទសួរពីការយកត្រលប់ទៅវិញ ឬបំផ្លាញចោលឱ្យបានសមស្រប ។

៣. ភាគីនីមួយៗ ត្រូវផ្តល់ព័ត៌មានទាក់ទងទៅនឹងករណីនៃចលនាឆ្លងដែនខុសច្បាប់ ដល់ការិយាល័យចែកចាយព័ត៌មានជីវសុវត្ថិភាព ដែលពាក់ព័ន្ធនឹងខ្លួន ។

## មាត្រាទី ២៦

## ការពិចារណាផ្នែកសេដ្ឋកិច្ចសង្គម

១. ភាគីចុះកិច្ចសន្យា មុននឹងឈានដល់សេចក្តីសំរេចលើការនាំចូលយោងលើពិធីសារ ឬ វិធានការនៅក្នុងប្រទេសរបស់ខ្លួនដោយអនុវត្តពិធីសារនេះ អាចគិតគូរឱ្យបានសមស្របទៅតាមកាតព្វកិច្ចអន្តរជាតិការពិចារណាសេដ្ឋកិច្ចសង្គម បណ្តាលមកពីផលប៉ះពាល់នៃសារពាង្គកាយកែច្នៃរស់ លើការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនៃជីវៈចំរុះ ជាពិសេសដើម្បីតំលៃនៃជីវៈចំរុះទៅលើសហគមន៍មូលដ្ឋាន និងជនជាតិភាគតិច ។

២. ភាគីចុះកិច្ចសន្យា ត្រូវលើកទឹកចិត្តអោយមានកិច្ចសហប្រតិបត្តិការលើការស្រាវជ្រាវ និងការផ្លាស់ប្តូរព័ត៌មានស្តីពីផលប៉ះពាល់នៃសារពាង្គកាយកែច្នៃរស់ លើសេដ្ឋកិច្ចសង្គម ជាពិសេសលើសហគមន៍មូលដ្ឋាន និងជនជាតិភាគតិច ។

## មាត្រាទី ២៧

## ការទទួលខុសត្រូវចំពោះច្បាប់ និង ការដោះស្រាយបញ្ហា

សន្និសីទភាគីដែលបំរើជាកិច្ចប្រជុំរបស់ភាគីចុះកិច្ចសន្យាទៅនឹងពិធីសារនេះ ត្រូវអនុម័តនៅក្នុងកិច្ចប្រជុំលើកដំបូងនូវដំណើរការមួយទាក់ទងទៅនឹងការពិពណ៌នានៃច្បាប់អន្តរជាតិ និងបែបបទលើការទទួលត្រូវមុខច្បាប់ និងការដោះស្រាយបញ្ហាការខូចខាតដែលបណ្តាលមកពីចលនាឆ្លងដែននៃសារពាង្គកាយកែច្នៃរស់ ធ្វើការវិភាគ និងគិតគូរពីដំណើរការកំពុងអនុវត្តនៅក្នុងច្បាប់អន្តរជាតិស្តីពីបញ្ហាទាំងនោះ ហើយត្រូវខិតខំប្រឹងប្រែងឱ្យអស់ពីសមត្ថភាព ដើម្បីសំរេចដំណើរការនេះក្នុងរយៈពេល ៤ ឆ្នាំ ។

## មាត្រាទី ២៨

## ធនធាន និងយន្តការហិរញ្ញវត្ថុ

១. ដោយគិតគូរពីធនធានហិរញ្ញវត្ថុ សំរាប់ការអនុវត្តន៍ពិធីសារនេះ ភាគីចុះកិច្ចសន្យាត្រូវគិតគូរពី " ៥" ដែលមានចែងនៅក្នុងមាត្រាទី ២០ នៃអនុសញ្ញានេះ។

២. យន្តការហិរញ្ញវត្ថុ ដែលត្រូវបានបង្កើតឡើងនៅក្នុងមាត្រាទី ២១ នៃអនុសញ្ញានេះ គឺជាយន្តការសំរាប់ពិធីសារនេះផងដែរ តាមរយៈរចនាសម្ព័ន្ធស្ថាប័នស្របទៅនឹងការអនុវត្តន៍របស់អនុសញ្ញានេះ ។

៣. ទាក់ទងទៅនឹងការកសាងសមត្ថភាព ដែលមានចែងក្នុងមាត្រាទី ២២ នៃពិធីសារនេះ សន្និសីទភាគីបំរើជាកិច្ចប្រជុំរបស់ភាគីចុះកិច្ចសន្យាទៅនឹងពិធីសារ ដោយផ្តល់ការណែនាំលើយន្តការចែងក្នុងកថាខ័ណ្ឌទី ២ ខាងលើ សំរាប់ពិចារណាដោយសន្និសីទភាគី ត្រូវគិតគូរពីតំរូវការធនធានហិរញ្ញវត្ថុដោយភាគីប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសប្រទេសមានការអភិវឌ្ឍន៍តិចតួចបំផុត និងប្រទេសកំពុងអភិវឌ្ឍន៍ជាកោះតូចៗក្នុងចំណោមពួកគេ ។

៤. នៅក្នុងអត្ថបទនៃកថាខ័ណ្ឌទី ១ ខាងលើ ភាគីចុះកិច្ចសន្យាត្រូវគិតគូរផងដែរពីតម្រូវការរបស់ភាគី ដែលជាប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសប្រទេសមានការអភិវឌ្ឍន៍តិចតួចបំផុត និងប្រទេសកំពុងអភិវឌ្ឍន៍ជាកោះតូចៗ និងតម្រូវការរបស់ភាគីមានសេដ្ឋកិច្ចអន្តរកាល នៅក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីកំណត់ និងអនុវត្តនូវតម្រូវការកសាងសមត្ថភាពរបស់ខ្លួន ក្នុងគោលបំណងដើម្បីអនុវត្តពិធីសារនេះ ។

៥. ការណែនាំអំពីយន្តការហិរញ្ញវត្ថុនៃអនុសញ្ញានេះ នៅក្នុងសេចក្តីសំរេចដែលពាក់ពន្ធ័របស់សន្និសីទភាគី រួមបញ្ចូលការព្រមព្រៀងមុននឹងអនុម័តពិធីសារនេះ ត្រូវអនុវត្តដោយមានការផ្លាស់ប្តូរសមរម្យចំពោះលក្ខខ័ណ្ឌនៃមាត្រានេះ ។

៦. ភាគីប្រទេសអភិវឌ្ឍន៍អាចឧបត្ថម្ភ ហើយភាគីប្រទេសកំពុងអភិវឌ្ឍន៍ និងភាគីដែលមានសេដ្ឋកិច្ចអន្តរកាលត្រូវត្រៀមខ្លួនទទួលធនធានហិរញ្ញវត្ថុ និងបច្ចេកវិទ្យាសំរាប់ការអនុវត្តន៍លក្ខខ័ណ្ឌនៃពិធីសារនេះ តាមរយៈកិច្ចព្រមព្រៀងទ្វេរភាគី តំបន់ និងពហុភាគី ។

## មាត្រាទី ២៩
## សន្និសីទភាគីបំរើជាកិច្ចប្រជុំរបស់ភាគីចុះកិច្ចសន្យាទៅនឹងពិធីសារនេះ

១. សន្និសីទភាគី បំរើជាកិច្ចប្រជុំរបស់ភាគីទាំងអស់ដែលចុះកិច្ចសន្យាទៅនឹងពិធីសារនេះ

២. ភាគីចុះកិច្ចសន្យាទៅនឹងអនុសញ្ញានេះ ដែលមិនមែនជាភាគីចុះកិច្ចសន្យាទៅនឹងពិធីសារនេះ អាចចូលរួមជាអ្នកសង្កេតការនៅក្នុងដំណើរការកិច្ចប្រជុំណាមួយនៃសន្និសីទភាគីដែលជាកិច្ចប្រជុំរបស់ភាគីចុះកិច្ចសន្យាទៅនឹងពិធីសារនេះ ។ នៅពេលសន្និសីទភាគីនេះ បំរើជាកិច្ចប្រជុំរបស់ភាគីចុះកិច្ចសន្យាទៅនឹងពិធីសារ សេចក្តីសំរេចនៅក្នុងពិធីសារនេះ ត្រូវធ្វើឡើងចំពោះតែភាគីចុះកិច្ចសន្យាទៅនឹងពិធីសារនេះ ។

៣. នៅពេលសន្និសីទភាគី បំរើជាកិច្ចប្រជុំរបស់ភាគីចុះកិច្ចសន្យាទៅនឹងពិធីសារ សមាជិកនៃការិយាល័យសន្និសីទភាគីដែលតំណាងអោយភាគីមួយចុះកិច្ចសន្យាទៅនឹងអនុសញ្ញានេះ ក្នុងខណៈនោះមិនមែនជាភាគីចុះកិច្ចសន្យាទៅនឹងពិធីសារនេះទេ ត្រូវជំនួសដោយសមាជិកមួយដែលនឹងត្រូវបានជ្រើសរើសតាំង ក្នុងចំណោមភាគីចុះកិច្ចសន្យាទៅនឹងពិធីសារនេះ ។

៤. សន្និសីទភាគីបំរើជាកិច្ចប្រជុំរបស់ភាគីចុះកិច្ចសន្យាទៅនឹងពិធីសារ ត្រូវធ្វើការត្រួតពិនិត្យឱ្យបានទៀងទាត់លើការអនុវត្តន៍ពិធីសារ ហើយត្រូវធ្វើសេចក្តីសំរេចដែលចាំបាច់ដើម្បីជំរុញការអនុវត្តន៍អោយមានប្រសិទ្ធភាពនៅក្នុងក្រោមតួនាទីរបស់ខ្លួន ។ សន្និសីទភាគី ត្រូវអនុវត្តនូវតួនាទីដែលបានផ្តល់ដោយពិធីសារ និងត្រូវៈ

ក. ផ្តល់អនុសាសន៍ទៅលើបញ្ហាដែលចាំបាច់សំរាប់ការអនុវត្តន៍ពិធីសារនេះ

ខ. បង្កើតអនុគណៈកម្មាធិការដែលចាំបាច់សំរាប់ការអនុវត្តន៍ពិធីសារនេះ

គ. ស្វែងរក និងប្រើប្រាស់ឱ្យបានសមស្របនូវសេវាកម្ម និងសហប្រតិបត្តិការ និងព័ត៌មានដែលផ្តល់អោយដោយអង្គការអន្តរជាតិ អង្គការអន្តររដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលមានសមត្ថកិច្ច

ឃ. បង្កើតទំរង់ និងគំលាតពេលវេលាសំរាប់ការផ្សព្វផ្សាយព័ត៌មានដែលត្រូវផ្តល់ឱ្យស្របទៅតាមមាត្រាទី ៣៣ នៃពិធីសារនេះ និងពិចារណាទៅលើព័ត៌មាន និងរបាយការណ៍ដែលដាក់ជូនដោយអនុគណៈកម្មធិការនេះ ។

